*<u>សូមពិនិត្យមើលមុននឹងចែកចាយ</u>*

# សម័យប្រជុំលើកទី ៣១ នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស

## របៀបវារៈទី១០

## ប្រទេសយេមែន និងប្រទេសកម្ពុជា

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER


**ថ្លែងដោយ អ្នកស្រី ឃេត ហ្គីលម័រ (Kate Gilmore)**

**ឧត្តមស្នងការរងអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស**


ទីក្រុងហ្សឺណែវ ២៧ កញ្ញា ២០១៦

សាលប្រជុំ XX  Palais des Nations

លោកប្រធាន សមាជិកនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស ឯកឧត្តម លោកជំទាវ សហការី និងមិត្តភ័ក្តិ ជាទីគោរព

រសៀលនេះ យើងមានរបាយការណ៍ពីរបស់លោកអគ្គលេខាធិការ និងឧត្តមស្នងការ ដែលបាន ដាក់បញ្ជូនក្រោមរបៀបវារៈទី ១០ ស្តីពីប្រទេសយេមែន និងប្រទេសកម្ពុជា។

ខ្ញុំសូមចាប់ផ្តើមអានរបាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការស្តីពីស្ថានភាពសិទ្ធិមនុស្សក្នុង **ប្រទេសយេមែន** អនុលោមតាមសេចក្តីសម្រេចលេខ ៣០/១៨។

..........................

***

ឥឡូវ ចូលដល់របាយការណ៍របស់យើង (A/HRC/33/39) ស្តីពីវឌ្ឍនភាពនៃការងាររបស់ការិយាល័យប្រចាំ **កម្ពុជា**របស់យើង ដែលបាន និងកំពុងធ្វើការជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លើបញ្ហាបញ្ហាជាច្រើន ដោយផ្តោតលើ ប្រធានបទតាមវិស័យចំនួនបួន៖ ពង្រីកលំហលទ្ធិប្រជាធិបតេយ្យ, សិទ្ធិសេដ្ឋកិច្ច និងសង្គម, ការលើកស្ទួយនីតិរដ្ឋ និងការគាំទ្រកំណែទម្រង់ពន្ធនាគារ។

ស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសបង្ហាញឲ្យឃើញនូវ**និន្នាការពីរ**។

ម្យ៉ាងវិញទៀត រយៈពេលធ្វើរបាយការណ៍ បានឃើញថា**មានវឌ្ឍនភាពជាលំដាប់លើបញ្ហាបច្ចេកទេសមួយចំនួន** ដែលត្រូវបានកំណត់នៅក្នុងរបាយការណ៍។

ឧទាហរណ៍ ការពង្រីកនូវ**មូលដ្ឋានទិន្នន័យគ្រប់គ្រងករណីរបស់យើង** នៅតាមតុលាការមួយចំនួន ក្នុងប្រទេសកម្ពុជា ដោយមានកិច្ចសហការជាមួយក្រសួងយុត្តិធម៌ អនុញ្ញាតឲ្យយើងទទួលបានមកវិញល្អប្រសើរជាងមុននូវព័ត៌មាន ករណី។

**ការប្រគល់នូវប័ណ្ណកម្មសិទ្ធដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច** ដែលបានជាប់គាំងអស់មួយរយៈពេល បានចាប់ផ្តើមឡើងវិញ ដោយមានកិច្ចសហការគ្នាល្អរវាងការិយាល័យរបស់យើង និងក្រសួងអភិវឌ្ឍន៍ជនបទ។

យើងបន្តធ្វើជាស្ពានដើម្បីតភ្ជាប់រវាងស្ថាប័នរដ្ឋនានាលើបញ្ហាសិទ្ធិមនុស្សអន្តរវិស័យជាច្រើន។ កិច្ចប្រជុំជាទៀងទាត់ ដែលបានប្រមូលផ្តុំមន្ត្រីតុលាការ មន្ត្រីពន្ធនាគារ និងមន្ត្រីនគរបាល ដើម្បីបានជួបប្រជុំគ្នា បានបន្តក្នុងគោលបំណង**បង្កើនកិច្ចសម្របសម្រួល**ទាំងនៅថ្នាក់គោលនយោបាយ ទាំងនៅថ្នាក់មន្ត្រីអនុវត្ត។

ក្រុមការងារថ្មីត្រូវបានបង្កើតឡើងដើម្បី**ដោះស្រាយជម្លោះរ៉ាំរ៉ៃ** ដូចជានៅក្នុងវិស័យដីធ្លី។ នាពេលថ្មីៗនេះ ការិយាល័យរបស់យើង ទើបតែត្រូវបានតែងតាំងដោយដៃគូអភិវឌ្ឍន៍ ដើម្បីសហការជួយសម្រួលដល់ក្រុមការងារបច្ចេកទេសលើវិស័យដីធ្លីជាមួយក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់។

**ការធ្វើកំណែទម្រង់ផ្សេងៗ**ក្នុងវិស័យអប់រំ កំណែទម្រង់រដ្ឋបាលសាធារណៈ ការចុះអត្រានុកូលដ្ឋាន និងការរៀបចំការបោះឆ្នោត ក៏នឹងទទួលបានជោគជ័យយ៉ាងសំខាន់ផងដែរ ហើយការិយាល័យរបស់យើងនឹងចូលរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងនានា រាប់ទាំង តួនាទីរបស់យើងក្នុងនាមជាសហអ្នកសម្របសម្រួលដល់ក្រុមការងារបច្ចេកទេសកំណែទម្រង់ច្បាប់ និងតុលាការ ដែលជារចនាសម្ព័ន្ធមួយក្នុងចំណោមរចនាសម្ព័ន្ធតាក់តែងគោលនយោបាយរួមគ្នាជាច្រើន ដែលបានបង្កើតឡើងដោយក្រសួងជំនាញទាំងឡាយ និងដៃគូអភិវឌ្ឍន៍នានា។

ម្យ៉ាងវិញទៀត **ទំនាក់ទំនងកាន់តែយ៉ាប់យ៉ឺនរវាងគណបក្សនយោបាយសំខាន់ទាំងពីរ** កំពុងធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់លទ្ធភាពរបស់ប្រជាជនកម្ពុជាក្នុងការអនុវត្តនូវសិទ្ធិជាមូលដ្ឋាននានារបស់ខ្លួន។

និន្នាការនេះត្រូវបានកត់សម្គាល់ឃើញតាមរយៈ**ការរាំងខ្ទប់ស្ទើរតែជិតឈឹងនៃការធ្វើបាតុកម្មណាមួយ**ដោយមនុស្សដែលសម្តែងនូវការកើតទុក្ខមិនសុខចិត្តរបស់ខ្លួន នាពេលថ្មីៗនេះ ដោយតាមរយៈការរាំងខ្ទប់នោះ ធ្វើឲ្យមានការរំលោភលើសិទ្ធិសេរីភាពសម្តែងមតិ និងការជួបប្រជុំដោយសន្តិវិធីរបស់ពួកគេ។

អ្នករិះគន់ជាច្រើន ជាពិសេស អ្នករិះគន់របស់បក្សប្រឆាំងនយោបាយ កំពុងតែប្រឈមនឹង**នីតិវិធីតុលាការ** ដែលធ្វើឡើងដោយប្រព័ន្ធតុលាការមួយ ដែលជារួម ត្រូវបានគេអស់ជំនឿលើ តាមរយៈករណីលេចធ្លោនានា ដែលបានធ្វើឡើងដោយមានការគោរពតិចតួចលើដំណើរការនីតិវិធីត្រឹមត្រូវ និងជាញឹកញយ ដោយមិនមានភស្តុតាងដាច់ស្រេចណាមួយសោះ។

មាន**ការគំរាមកំហែងសម្លាប់**ដល់អ្នកវិភាគសង្គម និងអ្នកនយោបាយលេចធ្លោនានា។

**ការបំភិតបំភ័យ**ដល់គណបក្សប្រឆាំង តាមរយៈ ការបង្ហាញកម្លាំងយោធា បានកើតឡើងមិនតិចជាងម្តងនោះទេ។ យោធាបានប្តេជ្ញាជាសាធារណៈ ការពារគណបក្សកាន់អំណាច និងមេដឹកនាំរបស់ខ្លួន ប្រឆាំងនឹងរាល់ការប្រឈមតតាំងទាំងអស់។

ក្របខ័ណ្ឌច្បាប់ដ៏ស្មុគស្មាញមួយ កំពុងត្រូវបានបង្កើតឡើង តាមរយៈ ច្បាប់បន្តបន្ទាប់មួយចំនួនដែលរឹតត្បិតដល់ការប្រព្រឹត្តទៅនៃអង្គការសង្គមស៊ីវិលឯករាជ្យ។ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ឆ្នាំ ២០១៥ ដ៏ចម្រូងចម្រាស់ ដែលបានបង្កើតមូលដ្ឋានផ្លូវច្បាប់ ក្នុងការបិទប្រតិបត្តិការ កម្រិតសកម្មភាពនានា ឬបន្ទច់បង្អាក់យ៉ាងការិយាធិបតេយ្យដល់សកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល និងសមាគម ដែលគេចាត់ទុកថា "អព្យាក្រឹត" នោះ កំពុងត្រូវបានយកមកប្រើជាសំអាង ដើម្បីទប់ស្កាត់សកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល ជាពិសេស អង្គការទាំងឡាយណាដែលសកម្មបំផុតក្នុងបញ្ហាសិទ្ធិមនុស្ស។ បញ្ហាជាច្រើនទៀតនៃរឿងរ៉ាវដូចគ្នានេះ គឺអាចធ្វើទៅបាន ក្រោមច្បាប់សហជីពថ្មី។

ជនទាំងឡាយដែលជឿថាកំពុងរស់នៅ ធ្វើការងារ ឬធ្វើអ្វីផ្សេងទៀតដោយពឹងអាស្រ័យលើដងផ្លូវ កំពុងត្រូវបាន**កៀរប្រមូលតាមទំនើងចិត្ត និងបានចាប់ឃុំខ្លួន** ដោយពុំមានការត្រួតពិនិត្យតាមផ្លូវតុលាការឡើយ។

នៅពេលដែលបរិស្ថានសិទ្ធិមនុស្សជាទូទៅត្រូវបានគេសម្គាល់ឃើញដោយការរឹតត្បិត និងការបំភិតបំភ័យបែបនេះ ជាពិសេស ទៅលើគណបក្សប្រឆាំង បើទោះបីជា នីតិវិធី និងឧបករណ៍ សម្រាប់ការបោះឆ្នោត គឺមានភាពល្អប្រសើរឡើងច្រើនជាងការបោះឆ្នោតមុនក៏ដោយ វាច្បាស់ណាស់ថា **បរិយាកាសនាពេលបច្ចុប្បន្នសម្រាប់ការបោះឆ្នោត** គឺមិនអំណោយផលដល់ការបោះឆ្នោតគួរឲ្យទុកចិត្ត និងត្រឹមត្រូវ ក្នុងឆ្នាំ ២០១៧ និងឆ្នាំ ២០១៨ ឡើយ។

រដ្ឋាភិបាលមានអំណាចក្នុងការកែលម្អស្ថានភាពនេះ ប្រសិនបើខ្លួនមានឆន្ទៈនយោបាយ។ ខ្ញុំសូមស្វាគមន៍ចំពោះ "ការឈប់វាយប្រហារគ្នាទៅវិញទៅមក" រវាងគណបក្សទាំងពីរ ដែលបានប្រកាសដោយលោកនាយករដ្ឋមន្ត្រី កាលពីពីរបីថ្ងៃកន្លងមកនេះ និងសូមលើកទឹកចិត្តឲ្យប្រើប្រាស់ការឈប់វាយប្រហារគ្នាទៅវិញទៅមកនេះ ដើម្បី

ឈានទៅរកដំណោះស្រាយចំពោះបញ្ហាទាំងនេះ។ ការិយាល័យរបស់យើងនៅក្នុងប្រទេសកម្ពុជាត្រៀមខ្លួនជាស្រេចយ៉ាងពេញលេញ ដើម្បី**ជួយរដ្ឋាភិបាលក្នុងការលើកស្ទួយនូវការធ្វើកំណែទម្រង់** នៅថ្នាក់គោលនយោបាយជាមួយនឹងសមភាគីទាំងអស់របស់រដ្ឋាភិបាល លើបញ្ហាសិទ្ធិមនុស្សជាច្រើន។ ដូចបញ្ហាផ្សេងទៀតដែរ យើងប្រតិបត្តិការទាំងនៅថ្នាក់ម៉ាក្រូ និងមីក្រូ ក្នុងគោលបំណងដើម្បីផ្តល់នូវជំនួយបច្ចេកទេស ជួយដល់មន្ត្រីអនុវត្តនៅគ្រប់កម្រិតទាំងអស់ ឲ្យអនុវត្តបទប្បញ្ញត្តិនៃសន្ធិសញ្ញាសិទ្ធិមនុស្សដែលរដ្ឋាភិបាលបានផ្តល់សច្ចាប័ន ព្រមទាំងយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់ និងអនុសាសន៍របស់នីតិវិធីពិសេសផងដែរ។ នៅពេលដំណាលគ្នានេះដែរ យើងជួយដល់ជនរងគ្រោះពីការរំលោភបំពាននានា ជាពិសេស អ្នកដែលងាយរងគ្រោះបំផុត ហើយយើងផ្តល់ការគាំទ្រដល់អង្គការសង្គមស៊ីវិល និងតួអង្គផ្សេងទៀត ក្នុងគោលបំណងដើម្បីពង្រឹងសមត្ថភាពរបស់ពួកគេក្នុងវិស័យសិទ្ធិមនុស្ស រាប់ទាំង សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ និងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយផងដែរ។ យើងបានចូលរួមក្នុងការតស៊ូមតិ នៅពេលដែលចាំបាច់។ វាគឺជាចំណុចប្រសព្វលើគ្រប់ទិដ្ឋភាពទាំងនេះនៃអាណត្តិរបស់យើងដែលរួមគ្នាជួយយើងឲ្យមានប្រសិទ្ធភាព និងរួមជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស។

ថ្ងៃនេះ ខ្ញុំសូមបញ្ជាក់ឡើងវិញថា ការិយាល័យ OHCHR នៅតែជាដៃគូយូរអង្វែង និងជិតស្និទ្ធរបស់រាជរដ្ឋាភិបាលក្នុងការជួយរដ្ឋាភិបាលឲ្យអនុវត្តការប្តេជ្ញាចិត្ត និងកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួន។ យើងត្រៀមខ្លួនរួចជាស្រេចក្នុងស្មារតីភាពជាដៃគូ ដើម្បីបន្ត**អនុស្សរណៈនៃការយោគយល់** ដែលឆ្លុះបញ្ចាំងយ៉ាងពេញលេញនូវការគោរពគ្នាទៅវិញទៅមកចំពោះភារកិច្ចរៀងៗខ្លួនរបស់យើង ហើយដាក់បញ្ហាសិទ្ធិមនុស្សជាចំណុចស្នូលនៃកិច្ចសហការរបស់យើង ដោយអនុលោមតាមធម្មនុញ្ញអង្គការសហប្រជាជាតិ។ សូមអរគុណ។